**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០២៦៣ ៥ធ.អធរ.សណាន

# សេចក្តីណែនាំ
## ស្តីពីការបង់ប្រាក់អត្ថប្រយោជន៍បន្ថែម មូលនិធិរ៉ែទ្រទ្រង់កច្ចអភិវឌ្ឍន៍សហគមន៍ មូលដ្ឋាន និងមូលនិធិសម្រាប់ការគ្រប់គ្រងនិងកសាងសមត្ថភាព ចំពោះធនធានរ៉ែសំណង់

ក្នុងគោលបំណងគ្រប់គ្រងឱ្យកាន់តែមានប្រសិទ្ធភាព ក្នុងការបង់ចំណូលវិស័យធនធានរ៉ែដែលអាជីវករ ក្រុមហ៊ុនធ្វើអាជីវកម្មធនធានរ៉ែសំណង់មានកាតព្វកិច្ចត្រូវបំពេញ ស្របតាមប្រកាសស្តីពីលក្ខខណ្ឌនៃអាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម និង លក្ខខណ្ឌកំណត់ផ្សេងៗសម្រាប់អាជ្ញាបណ្ណសិប្បកម្ម ក្នុងការធ្វើអាជីវកម្មធនធានរ៉ែសំណង់ ក្រសួងរ៉ែ និងថាមពល សូមធ្វើការណែនាំដល់មន្ទីររ៉ែ និងថាមពល រាជធានី ខេត្ត ដូចខាងក្រោម៖

### ១) ការបង់ប្រាក់អត្ថប្រយោជន៍បន្ថែម

ប្រាក់អត្ថប្រយោជន៍បន្ថែម គឺជាចំណូលធនធានរ៉ែបន្ថែមទៅលើសួយសារធនធានរ៉ែសំណង់ ដូចដែលបានកំណត់ក្នុងប្រកាសអន្តរក្រសួងលេខ២៨៤ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីអត្រាសួយសារលើតម្លៃធនធានរ៉ែ និងនីតិវិធីនៃការបង់ថ្លៃសួយសារ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល។ ការទូទាត់បង់ចំណូលប្រាក់អត្ថប្រយោជន៍បន្ថែម ត្រូវធ្វើរៀងរាល់ដំណាច់ត្រីមាសនីមួយៗ ទន្ទឹមនឹងការធ្វើស្វ័យប្រកាសសួយសាររ៉ែសម្រាប់ត្រីមាសបន្ទាប់។ ចំណូលប្រាក់អត្ថប្រយោជន៍បន្ថែម ត្រូវកត់ត្រាចូលទៅក្នុងខ្ទង់ចំណូលសួយសារធនធានរ៉ែ។

មន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ត្រូវគណនាប្រាក់អត្ថប្រយោជន៍បន្ថែមនេះ ដោយផ្អែកទៅតាមបរិមាណផលិតកម្មជាក់ស្តែងក្នុងត្រីមាសដែលអាជីវករ ក្រុមហ៊ុនបានប្រកាសក្នុង«លិខិតប្រកាសសួយសារធនធានរ៉ែ សម្រាប់ការធ្វើអាជីវកម្មរ៉ែសំណង់» ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនានា មានកិច្ចសន្យាទិញ-លក់ វិក្កយបត្រ ជាដើម។ មន្ទីររ៉ែ និងថាមពលរាជធានីខេត្តត្រូវចេញ«លិខិតបញ្ជាក់បង់ប្រាក់ចំណូលលើតម្លៃធនធានរ៉ែ»ជូនអាជីវករ ក្រុមហ៊ុន ដោយធ្វើការបែងចែកប្រាក់ដែលត្រូវបង់ចំណូលលើប្រាក់អត្ថប្រយោជន៍បន្ថែម និងអនុវត្តន៍បែបបទ

នៃការបង់ចំណូល ដូចគ្នានឹងការបង់ចំណូលសួយសារលើតម្លៃធនធានរ៉ែ ដែលបានកំណត់ស្រប តាមប្រការ៣ នៃប្រកាសអន្តរក្រសួងលេខ២៨៤ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥។

២) ការបង់ប្រាក់មូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន និងមូលនិធិ សម្រាប់ការគ្រប់គ្រងនិងកសាងសមត្ថភាព

ប្រាក់ដែលត្រូវបង់ចូលមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន និងមូលនិធិ សម្រាប់ការគ្រប់គ្រងនិងកសាងសមត្ថភាព ត្រូវគណនាដោយផ្អែកទៅតាមបរិមាណផលិតកម្ម ជាក់ស្តែងក្នុងត្រីមាស ដូចក្នុងខ្លឹមសារដែលបានថែងខាងលើ។ ប្រាក់មូលនិធិរ៉ែទ្រទ្រង់កិច្ច អភិវឌ្ឍន៍សហគមន៍មូលដ្ឋាន និងមូលនិធិសម្រាប់ការគ្រប់គ្រងនិងកសាងសមត្ថភាពត្រូវធ្វើការ ទូទាត់រៀងរាល់ដំណាច់ត្រីមាសនីមួយៗ ទន្ទឹមនឹងការធ្វើស្វ័យប្រកាសសួយសាររ៉ែសម្រាប់ត្រី មាសបន្ទាប់ ហើយត្រូវបង់មួយរយភាគរយចូលគណនីដូចខាងក្រោម៖

មូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន

ធនាគារ៖ ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB)

ឈ្មោះគណនី៖ MINING COMMUNITY DEVELOPMENT FUND

លេខគណនី៖ 010-30-064-000965-8

មូលនិធិសម្រាប់ការគ្រប់គ្រងនិងកសាងសមត្ថភាព

ធនាគារ៖ ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB)

ឈ្មោះគណនី៖ MINING TRAINING FUND

លេខគណនី៖ 010-30-064-000966-1

ក្រសួងសង្ឃឹមយ៉ាងមុតមាំលើស្មារតីទទួលខុសត្រូវរបស់អស់លោកប្រធានមន្ទីររ៉ែ និង ថាមពលរាជធានី ខេត្ត ក្នុងការអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ៕

ភ្នំពេញ ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៥

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ